អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបង្កើតឈិង**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**សិក្សាសង្គម** ៖ ចម្រៀងនិងតន្ត្រី៖ ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិតនិងបទពិសោធន៍ផ្នែកតន្ត្រី

៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយការបង្កើតរូបភាព

៖ គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈ ការបង្កើតរូបភាព។

**ភាសាខ្មែរ** ៖ ការស្គាល់តួអក្សរ៖ ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

ប្រាប់បានពីរបៀបធ្វើចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងអ្វីមួយ។

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីការទះដៃបន្ទរ ឬគោះសម្ភារនានា តាមចង្វាក់ភ្លេង។

បំណិនសម្បទា៖ ទះដៃបន្ទរ គោះសម្ភារនានាតាមចង្វាក់ភ្លេង។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ប្រាប់បានពីសូរសំឡេងសត្វឬវត្ថុនានានៅក្នុងបរិស្ថាន

បំណិនសម្បទា៖ បង្ហាញពីភាពខុសគ្នានៃសូរសំឡេង

**កម្រិតសិក្សា** ៖ ទាប មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សម្ភារដែលត្រូវត្រៀមមានដូចជា៖ កាំភ្លើងបាញ់កាវ ខ្សែអំបោះ ដែកឈាន តង្កៀបគាបសក់ កន្ត្រៃ កាំបិតកាត់ក្រដាសគម្របដបចំនួន៨និងក្រដាសកេស។

**ការរៀបចំ** ៖ បង្កើតជាឈិងនេះមួយសម្រាប់បង្ហាញទៅកាន់កុមារ មុននឹងឱ្យកុមារចាប់ផ្តើមលេង ឬបង្កើត។

**សេចក្តីណែនាំ** ៖

1. ដំបូងសួរកុមារពីឧបករណ៍តន្ត្រីជាមុនសិន ថាតើកុមារស្គាល់វាបានប៉ុន្មាន? តើកូនស្គាល់ឈិងដែរឬទេ?
2. ប្រាប់កុមារទាំងអស់ថា ថ្ងៃនេះពួកយើងនឹងបង្កើតជាឧបករណ៍តន្ត្រីមួយដែលមានឈ្មោះថា ឈិង។

3. តើកូនៗចង់ចេះបង្កើតឈិងដែរឬទេ?
4. គ្រូបង្ហាញឈិងដៃគ្រូបានបង្កើតនិងបានត្រៀមសម្រាប់បង្ហាញកុមារ ជាមុនសិននិងបន្ទាប់មក ប្រាប់កុមារពីរបៀបធ្វើវាជាមុនសិនដែរ ។
    - ★ ក្រដាសកេសគូរជារង្វង់ពីរដោយប្រើដែកឈាន
    - ★ កាត់វាជារង្វង់តាមការគូសនៅលើក្រដាសកេសមុនហ្នឹង
    - ★ ប្រើគម្របដបប្រាំបី បិទលើក្រដាសកេសរង្វង់ បិទវាដោយប្រើកាំភ្លើងបាញ់កាវ ម្ខាងបួនគម្របដប
    - ★ ចុងក្រោយ ប្រើដែកឈានចោះរន្ធពីរសម្រាប់ចងវា
    - ★ ប្រើខ្សែដាក់ចូលទៅក្នុងរន្ធដែលបានចោះមុនហ្នឹង
    - ★ ដោយប្រើតង្កៀបគាបសក់ជួយក្នុងការស៊កវាចូល
    - ★ ខ្សែកាត់ឱ្យល្មមស៊កដៃចូល មិនតឹងពេក មិនរលុងពេក
    - ★ បន្ទាប់ពីស៊កខ្សែចូលរួច ត្រូវក្លួចចុងខ្សែ កុំឱ្យវារបូតវិញបែបនេះ
    - ★ មួយសម្រាប់ដៃស្តាំនិងមួយសម្រាប់ដៃឆ្វេង។
    - ★ បន្ទាប់មក ពួកយើងនឹងទទួលបានឈិងមួយដែលពួកយើងបានបង្កើតដោយខ្លួនឯងតែម្តង។
    - ★ នាំពួកគេលេងឈិងដែលបានបង្កើតដោយគោះវា ម្តងម្នាក់ ឬបង្កើតឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
5. សម្រាប់ការបង្កើតឈិងនេះ វាគ្រាន់តែជាការលើកជាឧទាហរណ៍ទេ អ្នកអាចបង្កើតជាមួយសម្ភារផ្សេងៗក៏បានដែរ ឱ្យតែស្រួលសម្រាប់ការបង្កើតរបស់អ្នក ដូចជាការស្វែងរកសម្ភារជាដើម…។